ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខៈ ១៤០៩ ប្រក

# ប្រ កា ស

## ស្តីពី

## ការតែងតាំងមុខតំណែងមន្ត្រីរាជការ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រី រាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃ ក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់ក្រសួងមហាផ្ទៃ

## <u>ស ម្រេ ច</u>

<u>**ប្រការ១**</u> ៖ ត្រូវបានតែងតាំងមុខតំណែងមន្ត្រីរាជការចំនួន ០៣រូប ជា**អភិបាលរង**នៃគណៈអភិបាលក្រុងសៀមរាប ខេត្តសៀមរាប ដូចមានរាយនាមខាងក្រោម ៖

| | |
|---|---|
| ១- លោក **សួរ ឈួតុង** | អភិបាលរងក្រុង |
| ២- លោកស្រី **គុយ វិសាល** | អភិបាលរងក្រុង |
| ៣- លោក **អឿន ពៅ** | អភិបាលរងក្រុង ។ |

**ប្រការ ២ ៖** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣ ៖** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អភិបាលខេត្តសៀមរាប ប្រធាននាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈក្រសួងមហាផ្ទៃ និង សាមីខ្លួន ដែលមានឈ្មោះក្នុងប្រការ១ខាងលើ ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៩*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**កន្លែងទទួល ៖**

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ*
- *រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ*
  *" ដើម្បីជូនជ្រាប "*
- *ដូចប្រការ ៣ ( ដើម្បីអនុវត្ត )*
- *ឯកសារ— កាលប្បវត្តិ*